ក. ២០៣

លេខ ៥



ទស្សនាវដ្ដីចេញរាល់ខែ

ក 203

ថ្ងៃ១ មករា ឆ្នាំ ១៩៥៧

ឆ្នាំទី ២ លេខ ៤ ខែមករា ១៩៥៣

# ទស្សនាវដ្តី

# នៃសមាគមសាមគ្គីសិស្សចាស់នឹងមិត្តសិស្សចាស់

# នៃអនុវិទ្យាល័យ នឹងវិទ្យាល័យស៊ីសុវត្ថិ

ទីសំណាក់ការ លេខ ១៣០ វិថីប៉ាស្ទ័រ ភ្នំពេញ

ក. 203

# មាតិការរឿង

ទំព័រ

វិចារណកថា ................ ១

អក្សរសាស្ត្រ– បញ្ហាភាសាជាតិ ................ ៦

ការត្រូវការរបស់សេដ្ឋកិច្ចយើង ................ ១៣

ប្រវត្តិសាស្ត្រ–ពង្សាវតារព្រែកជីកស៊ុយអេ ................ ១៩

អនាម័យ – គ្រឿងបរិភោគ ................ ២២

យុវជនខ្មែរនឹងលោកជូអេនឡាយ ................ ៣៤

រឿងកំសាន្ត ................ ៣៨

ដំណឹងផ្សេងៗ ................ ៤៥

## ដម្លៃជាវ

ក្នុងប្រទេស

| ១ក្បាល | ៦ខែ | ១ឆ្នាំ |
|---|---|---|
| ១០រ | ៥០រ | ១០០រ |

ក្រៅប្រទេស

| ១ក្បាល | ៦ខែ | ១ឆ្នាំ |
|---|---|---|
| ១៣រ | ៦០រ | ១២០រ |

សូមផ្ញើអាណត្តិទៅលោក សុគា-គាល លេខ១៣០ វិថីបាស្ទ័រ ភ្នំពេញ

# វិចារណកថា

គណកម្មាធិការនាយកនៃសមាគម សូមអភ័យទោសដល់សមាជិកទាំងមិត្តអ្នកអានទាំងឡាយ នូវការខកខានពុំបានចេញទស្សនាវដ្តី កន្លងមុនទាំងយឺតយូរកន្លងមកនេះ ។

សមាគមយើងបានប្រាថ្នាថា នឹងចេញទស្សនាវដ្តីជូនអស់លោកសមាជិក មិត្តអ្នកអានឲ្យបានរាល់ខែ ដូច្នេះការអាក់ខាននេះ ជាករណីវិបត្តិមួយ ដែលគួរតែយើងជួយពិចារណា ហើយជួយដោះស្រាយ ។

ក្នុងរឿងចេញទស្សនាវដ្តីនេះ គណកម្មាធិការនាយកបានសម្រេចដូចតទៅ :

១- ចេញទស្សនាវដ្តីមួយរៀងរាល់ខែ,

២- សមាគមជួយសោហ៊ុយបោះពុម្ពក្នុងមួយលេខ២៥០០រៀល បើចេញទៅហើយខាត,

៣- បើខាតក្នុងមួយលើកលើសពី៥០០រៀលទៅ សមាគមនឹងឈប់ចេញ ។

ដូចអស់លោកទាំងឡាយ ជ្រាបស្រាប់ហើយ សមាគមយើងនេះកើតឡើងមិនមែនសំរាប់តែធ្វើការមួយមុខទេ នៅមានគោលបំណងច្រើនទៅទៀត ។ ដូចជាការពលិកម្មដែលសមាគមហ៊ានធ្វើ គឺចេញប្រាក់ ៥០០ រៀលទៀតក្នុងមួយខែ ៗ ឃើញថាច្រើនណាស់ទៅហើយ ។

ទល់មកដល់សព្វថ្ងៃនេះ ទស្សនាវដ្ដីវិជ្ជា បានចេញបួនលេខហើយ គិតទាំងលេខនេះ ។ ក្នុងការចេញទស្សនាវដ្ដីនេះ យើងខ្ញុំជាគណកម្មាធិការនាយកបានជួបប្រទះនឹងឧបសគ្គជាច្រើន ។ ឧបសគ្គដែលសំខាន់ជាងគេគឺ:

១ - អំពីអត្ថបទ

២ - អំពីការចាត់ចែងលក់

១- អំពីអត្ថបទ.- ក្នុងការស្វែងរកអត្ថបទដ៏មានខ្លឹមសារ ជាការពិបាកណាស់ ។ តាំងពីទស្សនាវដ្ដីនេះចេញមក ពុំសូវមានសមាជិកណាអើរពើក្នុងរឿងនេះទេ គឺថាសមាជិកពុំសូវយកចិត្តទុកដាក់ក្នុងការអប់រំខ្លួនទៅៗ បើតាមយើងសង្កេតទៅ ឃើញថាការពុំសូវអើរពើនេះមកតែពីបរិយាកាសនយោបាយស្រុកយើងសព្វថ្ងៃ ។ បំផុតទៅបច្ចុប្បន្នកាលនេះ ក្នុងដំណើរពង្រឹងឯករាជ្យស្រុកយើងប្រទះនូវឧបសគ្គគ្រប់យ៉ាង ។ សត្រូវកំពុងរកគ្រប់មធ្យោបាយបំបាត់នូវឯករាជ្យ អធិបតេយ្យភាពយើង ។ ហេតុនេះយើងគ្រប់

រូបត្រូវតែខ្វល់ ត្រូវតែជួយដោះ ជួយពង្រឹងឯករាជ្យយើង ព្រោះយើងទាំងអស់គ្នាដឹងជាក់ហើយ បើគ្មានឯករាជ្យទេ ក៏គ្មានវឌ្ឍនភាពដែរ ៗ

តែក្នុងការខ្វល់របស់យើង ៗ ក៏មិនត្រូវភ្លេចការកសាងដែរ គឺកសាងគ្រប់ផ្នែក ពិសេសក្នុងនាទីនេះ យើងជួយរួបរួមកសាងវប្បធម៌យើងឲ្យបានលូតលាស់ឡើង ដោយយើងដឹងច្បាស់ថា បើយើងបានឯករាជ្យទេ គ្មានការកសាងផ្នែកឯទៀត ៗ ទេ ឯករាជ្យយើងក៏មិនរឹងប៉ឹងដែរ ៗ

២– អំពីការចាត់ចែងលក់ – ក្នុងការនេះ យើងគង់ជ្រាបហើយថា សមាជិកនៃគណៈកម្មាធិការនាយកមិនមែនរស់ដោយសារសមាគមទេ ៗ សមាជិកម្នាក់ ៗ មានរបរផ្សេង ៗ ហើយមកធ្វើការឲ្យសមាគមនេះតាមពេលទំនេរទៅ ៗ ដូច្នោះឃើញថា ដល់បានទស្សនាវដ្តីហើយ បញ្ហាមួយធំគឺការចាត់ចែងលក់ ៗ របៀបមួយមកឃើញស្រួលបន្តិច គឺដាក់លក់តាមបណ្ណាគារដែលមាននៅគ្រប់ទីកន្លែង ៗ តែបើធ្វើយ៉ាងនេះទៅឃើញថាពិបាក ៗ ពិបាកមកពីទស្សនាវដ្តីចេញរាល់ខែមិនអាចតាំបានយូរ ដូចប្រលោមលោកដែលគេចេញតែមួយដងរហូតទៅ ៗ មានវិធានការណ៍មួយទៀត គឺដើរលក់ តែវិធានការណ៍នេះ ក៏ពិបាកនឹងសម្រួលតាមរបរយើងម្នាក់ៗណាស់ ៗ នៅមានវិធានការណ៍

តែម្យ៉ាងទេ គឺរកអ្នកជាវឲ្យបានច្រើន ។

នេះជាឧបសគ្គខ្លះដែលមានមក ។ ក្នុងការទទួលខុសត្រូវក្នុងការចាយវាយទ្រព្យសមាគម គណៈកម្មាធិការនាយកក៏បានផ្អាកមួយលេខ ដើម្បីនឹងពិនិត្យដំណើរការរបស់ទស្សនាវដ្ដី ។ ក្នុងការពិនិត្យនេះយើងបានឃើញគុណសម្បត្តិដូចតទៅ :

១- ទស្សនាវដ្ដីដែលចេញមួយលើក ៗ ៥០០ ក្បាល លក់ដាច់អស់ ។

២- មានមិត្តអ្នកអានជាច្រើនបានសរសើរហើយយកទៅរៀន ។

៣- សមាជិកគណៈកម្មាធិការព្រមទាំងសមាជិកសមាគមខ្លះបានជួយខ្នះខ្នែងផ្សាយ ។

ឯគុណវិបត្តិវិញ មានដូចខាងក្រោម :

១- ពិតមែនតែចេញមួយលើក ៗ លក់ដាច់អស់ តែពុំសូវមានអ្នកជាវ

២- ការប្រមូលថ្លៃលក់ថ្លៃជាវពុំសូវបាន ។

តាមការពិនិត្យនេះទៅឃើញថា ទស្សនាវដ្ដីយើងមានប្រយោជន៍ មានខ្លឹមសារ ដល់ជាទីសង្ឃឹមរបស់យើង ។ គណៈកម្មាធិការនាយកក៏បានសម្រេចថានឹងចេញទស្សនាវដ្ដីតទៅទៀត ហើយសម្រេចចាត់វិធានការណ៍

យ៉ាងណាទំនងធ្វើឲ្យមានអ្នកជាវកាន់តែច្រើន ដើម្បីឈានទៅរកទិសដៅរបស់ សមាគម ។

ដូច្នោះទស្សនាវដ្ដីយើងនេះមានអនាគតល្អ សូមសមាជិកមិត្តទាំងឡាយ យកចិត្តទុកដាក់ផ្សាយ យកចិត្តទុកដាក់ជាវឲ្យបានច្រើន ហើយផ្ញើតម្លៃជាវ ឲ្យបានទាន់ពេលវេលា ។

គណៈកម្មាធិការនាយក

---

## អ្នកឯងច្រឡំទេ

–ខ្ញុំដូចជាធ្លាប់ឃើញមុខអ្នកឯងនៅឯណា ម្ដង ?

–មិនមែនទេ! តាំងពីកើតមក មុខខ្ញុំនៅតែមួយកន្លែងពីដើម ជាប់នឹងខ្លួនខ្ញុំ ។

X

X X

# ទំព័រអក្សរសាស្ត្រ

## (បញ្ហាភាសាជាតិ)

បញ្ហាប្រើភាសាជាតិក្នុងការសិក្សាជាតិ ជាបញ្ហាប្រកបដោយភាពបច្ចុប្បន្នបំផុត ។

តើយើងត្រូវប្រើភាសាជាតិក្នុងការសិក្សាជាតិឬទេ ?

យើងគ្រាន់តែនឹកទៅពាក្យ « ភាសាជាតិនឹងការសិក្សាជាតិ » ដែលយើងបានប្រើក្នុងឃ្លាខាងលើនេះ យើងរកឆ្លើយថាទេមិនរួចឡើយ ។ បើការសិក្សាជាតិមិនប្រើភាសាជាតិទេ ចុះហៅថាការសិក្សាជាតិម្ដេចបាន ? តែនៅមានបងប្អូនរួមជាតិជាច្រើនបារម្ភ ក្រែងប្រើភាសាជាតិក្នុងការសិក្សាយើងមិនកើតព្រោះ :

ក - ខ្លាចក្រែងចំណេះនៃសិស្សយើងអន់ថយ បើប្រើភាសាជាតិទៅ

ខ - ខ្លាចក្រែងខ្វះសៀវភៅជាភាសាខ្មែរយើង

គ - ខ្លាចក្រែងខ្វះគ្រូខ្ពស់ៗ

ឃ - ខ្លាចក្រែងខ្វះសាលាឲ្យកូនរៀនដល់ទៅថ្នាក់ខ្ពស់ៗទៀត បងប្អូនរួមជាតិដែលបានចិញ្ចឹមសេចក្ដីបារម្ភនេះជាការប្រសើរមួយហើយ ព្រោះ

សុទ្ធតែជាអ្នកគិតទៅប្រយោជន៍ជាតិទាំងអស់ គឺថាខ្វាចក្រែងនិស្សិតខ្មែរដែលចេញពីសាលាខ្មែរ មិនប្រកបដោយវិជ្ជាជ្រៅជ្រះស្មើនឹងវិជ្ជាបរទេស ។ ខ្វាចក្រែងយុវជនយើងមិនចេះបំពេញការងារជាសាធារណៈ ដូចយុវជនជាតិឯទៀត ៗ ។ តែបើដញ្ជឹងឲ្យមែនទែនទៅឃើញថា សេចក្តីបារម្ភនេះដែលកើតឡើងដោយសារយកភាសាខ្មែរមកប្រើ ទៅជាប្រឆាំងនឹងប្រយោជន៍ជាតិ ហើយប្រែត្រឡប់ទៅជាការពារប្រយោជន៍បរទេសឬការពារប្រយោជន៍ជនភាគតិចខ្លះទៅវិញ ។

សូមបងប្អូនជ្រាបថា កិច្ចបង្ខំរបស់បារាំងឲ្យយើងរៀនជាភាសាជាតិគេនោះជាអំពើជិះជាន់មួយក្តៅក្រហាយបំផុតលើប្រជាជនខ្មែរយើង ។ ចុះបើឥឡូវស្រុកយើងរួចពីកណ្តាប់ដៃគេហើយ តើនៅប្រើជាភាសាគេដល់ណាទៀត?

អ្នកខ្លះឆ្លើយថា ខ្មែរមិនមែនចង់ធ្វើបាបខ្មែរនោះទេ តែយើងបារម្ភក្រែងជំរេះនិស្សិតយើងដុនដាប ទើបមិនហានយកភាសាខ្មែរមកបង្រៀនជាភាសាសំខាន់នោះ ។ យកភាសាខ្មែរមកប្រើ ធៀបដូចលោតពីទីមួយដែលធ្លាប់ស្គាល់ធ្លាប់ស្រួលទៅទីមួយងងឹតស្ងួន ។ នេះក្រែងនាំឲ្យវង្វេង នាំឲ្យខូចការសិក្សាយើង ។ យើងសូមឆ្លើយថា បើទុកភាសាបារាំងជាភាសាសំខាន់ដដែល ជំរេះនិស្សិតខ្មែរគេតែអន់ថយ ជាងប្រើភាសាយើងទៅទៀត ហើយ

ប្រជាជនខ្មែរទូទៅនៅទីងងឹតដែល ព្រោះរកសៀវភៅជាភាសាជាតិមើលមិនបាន ដូចកាលជំនាន់បារាំងអញ្ចឹង ។

ព្រោះអ្វីបានជាការសិក្សាយើងដុនដាបបើយើងនៅប្រើភាសាបារាំង ?

បើយើងប្រើភាសាបារាំងជាភាសាសំខាន់ យើងនៅតែពឹងសាស្ត្រាចារ្យបារាំងមកបង្រៀនដូចជាន់មុន ។ យើងសូមជំរាបថា ក្នុងពេលឥឡូវនេះ សាស្ត្រាចារ្យបារាំងបង្រៀនមិនសូវបានផលទេ ព្រោះរដ្ឋាភិបាលបារាំងគេបញ្ជូនមកឲ្យយើងតែបុគ្គលណាដែលមានសមត្ថភាពស្ទួចស្តើង ហើយគេពិនិត្យមតិនយោបាយទៀតផង ។ សាស្ត្រាណាដែលមានឆន្ទៈល្អចង់បណ្តុះបណ្តាលយុវជនខ្មែរមែនទែនគេមិនសូវឲ្យមកទេ ។ ម្យ៉ាងទៀតវិជ្ជាខាងភាសាបារាំងរបស់សិស្សយើងសព្វថ្ងៃទន់ខ្សោយណាស់ គ្នាគេស្តាប់សំដីគ្រូបារាំងមិនបានផង ។ ដោយហេតុស្តាប់មិនយល់អ្វី ដោយហេតុគ្រូបារាំងដែលមានសមត្ថភាពស្ទួចស្តើងនោះគេពន្យល់មិនបានក្បោះក្បាយ សេចក្តីសៅហ្មងកើតមានឡើងក្នុងចិត្តសព្វទុក្ខ ។ គ្រូបារាំងត្អូញត្អែថាសិស្សខ្សោយពេក សេចក្តីអស់សង្ឃឹមក៏ធុញទ្រាន់នឹងបង្ហាត់ ចូលក្នុងថ្នាក់ធ្វើការខ្ជីខ្ជាឲ្យគ្រប់តែពេល ។ ចំណែកសិស្សនឹកថាគ្រូមិនកើតក៏អស់សង្ឃឹមលែងចង់រៀនសូត្រ ។ ការទាស់ទែងគ្នាកើតមានឡើងក្នុងសិស្សគ្រប់រូប ដូចកាលការទាស់ទែងនេះ

ក៏ផ្ទុះកើតទៅជាប្ដឹងផ្ដល់គ្នាក៏មាន ។ មិនតែប៉ុណ្ណោះសោតការទាស់ទែងគ្នានេះនាំឲ្យវិន័យក្នុងសាលាទាំងមូលខូចខាតអស់ៗ សិស្សលែងស្ដាប់គ្រូ លែងស្ដាប់អ្នកត្រួតត្រា គំនិតបះបោរកើតមានរហូតដល់ទៅពេលចេញផុតពីសាលាទៅទៀត ។ ដូច្នេះសាស្ត្រាចារ្យបារាំងនាំឲ្យសិស្សយើងខូចខាងផ្លូវចិត្តផងខាងផ្លូវបញ្ញាផង ។

មួយទៀតដោយហេតុថា «បារាំងមិនបារាំងខ្មែរមិនខ្មែរនេះ» ការសិក្សាខ្មែរអន់ថយបន្តិចម្ដងៗ ដំរេះនិស្សិតនឹងដំរេះប្រជាជនខ្មែរទូទៅកាន់តែដុនដាបបន្តិចម្ដងៗ ។ អំណើសតទៅសេចក្ដីសង្ឃឹមថា នឹងមាននិស្សិតខ្មែរដែលបានជាប់សញ្ញាបត្រធំៗឯស្រុកបារាំងមកធ្វើសៀវភៅជាភាសាខ្មែរ ឬមកធ្វើគ្រូៗសេចក្ដីសង្ឃឹមនោះរលត់សូន្យឈឹង ព្រោះសិស្សបេះៗនោះត្រឡប់ជាចិញ្ចឹមគំនិតចង់មានចង់ធំបោះបង់ចោលការឧបត្ថម្ភដល់អក្សរជាតិ ដូច្នេះអនាគតរបស់វប្បធម៌ខ្មែរបានជាមិនទូលំទូលាយសោះឡើយ ។

សមត្ថភាពគ្រូខ្សោយ គ្រូបារាំងខ្លះមិនព្រមរវល់នឹងបង្រៀនឲ្យស្រួលបួលផង សមត្ថភាពសិស្សខ្មែរខ្សោយខាងភាសាបារាំង នេះនាំឲ្យការសិក្សាយើងរួញបន្តិចម្ដងៗ ។ យុវជនខ្មែររអ៊ូរទាំរកកម្លាំងនឹងរៀនមិនកើត គ្មានចេះដំរេះអ្វីជ្រៅជ្រះ ។ ហេតុនេះបានជាយើងត្រូវគិតទៅអនាគតរបស់

ការសិក្សាយើង ៗ ធ្វើដូចម្ដេចឲ្យអនាគតនៃការសិក្សាយើងប្រកបទូវ សេចក្ដីសង្ឃឹមខ្លះផង ?

បើយើងទុកភាសាបារាំងជាភាសាសំខាន់ សិស្សយើងរិតតែអន់ខ្សោយ ទៅទៀត យើងត្រូវតែយកភាសាខ្មែរមកប្រើជាផ្លូវការក្នុងសាលាយើង ហើយត្រូវតែយកមកប្រើក្នុងពេលឆាប់ៗនេះ ព្រោះក្នុងពេលឥឡូវនៅមាន ខេមរៈជនជាច្រើន គ្រូខ្មែរជាច្រើនដែលចេះភាសាបារាំងយ៉ាងស្ទាត់ ៗ លោកអស់នេះមិនសូវប្រកបទូវវិជ្ជាសាស្ត្រជ្រៅជ្រះមែនហើយ ព្រោះបារាំង គេច្រើនឲ្យរៀនតែភាសាសម្រាប់ធ្វើជា «ចិបក» តែដោយចេះភាសាបារាំង ជ្រៅជ្រះ លោកអស់នោះអាចនឹងទៅក្រេបយកវិជ្ជាសាស្ត្រពីគម្ពីរបារាំង ឬពី មហាវិទ្យាល័យបារាំងមកបកប្រែជាភាសាខ្មែរ ឬក៏មកបង្រៀនជាភាសា ខ្មែរឲ្យកូនខ្មែរស្រួលស្ដាប់ស្រួលយល់បាន ៗ តែបើមិនប្រើភាសាខ្មែរជា ប្រញាប់ទេ យូរបន្តិចទៀតកូនខ្មែរចេះភាសាបារាំងតិចទៅៗមិនអាចទៅក្រេប យកវិជ្ជាសាស្ត្រធំៗបានទៀត ទុកជារាជការបញ្ជូនទៅច្រើនយ៉ាងណាក៏ ដោយក៏មិនអាចទៅយល់ការសិក្សាជាភាសាគេ ឲ្យបានដូចគេអ្នកចេះភាសា នោះបានឡើយ ៗ បើដូច្នោះហើយទៅពេលក្រោយយើងនឹងលែងមាន គ្រូខ្មែរតែហូត លែងមានសៀវភៅខ្មែរតែហូត បើមានក៏មានតែសៀវភៅ

កំទេចកំទីរដ្ឋបសព្វថ្ងៃនេះ ។ ជំរេះរបស់ប្រជាជនខ្មែរក៏រៀវរួញទៅ រកតែអ្នកកសាងជាតិឲ្យមានសមត្ថភាពមាំមួនមិនបាន ។

សង្ខេបមកយើងយល់ថា ទុកភាសាបារាំងជាផ្លូវការក្នុងការសិក្សាយើងក្នុងកាលៈទេសៈឥឡូវ នាំឲ្យការសិក្សាខ្មែរអន់ថយ បំផ្លិចអនាគតនៃការសិក្សាយើងទៀត ។ យើងត្រូវយកភាសាជាតិមកប្រើក្នុងពេលចាប់ៗនេះ ត្រូវគ្រូខ្មែរដែលមានសមត្ថភាពគ្រាន់បើមកបង្រៀនជំនួសបារាំង បញ្ជូនគ្រូខ្លះឲ្យទៅបំពេញវិជ្ជាឯមហាវិទ្យាល័យស្រុកបារាំងបណ្ដើរៗ ឲ្យបកប្រែសៀវភៅភាសាខ្មែរបណ្ដើរៗ ។ ដែលធ្វើយ៉ាងនេះបាន ហើយកុំឲ្យការសិក្សាយើងដុនដាបពេក ពាល់តែខំ គ្រូក៏ត្រូវខំ រដ្ឋាភិបាលក៏ត្រូវខំ ។ រដ្ឋាភិបាលត្រូវចំណាយប្រាក់ឲ្យច្រើនបន្តិចទៅ ចំពោះក្រសួងសិក្សាធិការទើបបាន ។ យើងក៏ដឹងដែរថាប្រាក់ថវិកាជាតិខ្វះខាតជាច្រើនក្នុងពេលឥឡូវ តែបើចង់ឲ្យស្រុកយើងដើរទៅកាន់សេចក្ដីចំរើន យើងត្រូវតែខំសាងការសិក្សាបន្តិច ។ សព្វថ្ងៃយើងឃើញថា ចំណាយរបស់រដ្ឋាភិបាលចំពោះទៅក្រសួងសិក្សាធិការមានប្រហែលតែ ៨ នៃថវិកាជាតិយើងប៉ុណ្ណោះ ចំនួននេះស្តួចស្តើងណាស់ បើយើងធៀបទៅស្រុកគេឯទៀតស្រុកគេឯទៀត ដូចជាស្រុកអង់គ្លេស ២២% សហរដ្ឋអាមេរិក ២១ ស្រុកចិនប្រជា

មាទិត្យ ១៤% ។ល។

ដូច្នេះគួរតែយើងខំបន្ដិបដើម្បីនឹងឲ្យការសិក្សាយើងមានដំណើរជឿនលឿន ដំបូងបង្អស់ខំប្រឹងយកភាសាខ្មែរមកប្រើក្នុងការសិក្សាខ្មែរឲ្យបាន យកបុគ្គលិកខ្មែរឲ្យធ្វើការក្នុងការសិក្សាខ្មែរ យកបញ្ហាខ្មែរឲ្យសិស្សខ្មែររៀនដោះស្រាយ ។ល។

---

## មិនមែនខុសពីគាត់ទេ!

ពូមែនទៅផ្សារបានទិញសត្វសេកមួយ ផ្ញើមកឲ្យមីងសៅជាប្រពន្ធ ។ ដល់ថ្ងៃត្រង់ គាត់ត្រឡប់មកផ្ទះវិញសួរទៅមីងសៅថា :

—ឯណាសេកដែលអញផ្ញើមកឲ្យ ?

—អញប្រឡាក់អំបិលអាំងទុកឲ្យឯងហូបបាយ

—អាំងទៅហើយ ! ឯងឡប់ខួរដែរឬ ? សេកនោះចេះនិយាយផង !

—បើអីចឹងមេចក៏វាមិនថាអីមួយអឺះសោះ កាលអញរៀបប្រឡាក់អំបិល ?

X

X X

# បញ្ហាសេដ្ឋកិច្ច

## ការត្រូវការរបស់សេដ្ឋកិច្ចយើងក្នុងបច្ចុប្បន្នកាលនេះ

ឯករាជ្យភាពប្រទេសយើងទើបនឹងមានអាយុ បានប្រហែល ៣-៤ ឆ្នាំទេ ។ ឯករាជ្យភាពនេះ បានដាស់រំលឹកសតិដល់ យុវជន-ប្រជាជន យើងឲ្យនឹកឃើញទៅដល់បញ្ហាកសាងប្រទេសជាតិមាតុភូមិ ។ ជនជាតិខ្មែរគ្រប់រូប ទាំងអ្នករាជការ មន្ត្រី ទាំងប្រជាជនសាមញ្ញ យើងត្រូវមានគំនិតជួយរួមកម្លាំង ដើម្បីស្ថាបនាប្រទេសយើងជាដាច់ខាត ។ ទាល់តែមានស្មារតីមានគំនិតនេះ ទើបយើងនឹងសន្មត់ថា យើងនឹងអាចការពារឯករាជ្យភាពប្រទេសជាតិឲ្យឋិតថេរបេរកាល ។

រហូតមកដល់សព្វថ្ងៃនេះ ប្រទេសខ្មែរយើងប្រកបផលខាងកសិកម្មសុទ្ធ ៗ នៅក្រុងភ្នំពេញដែលជារាជធានី គេពុំទាន់ឃើញមានរោងចក្រអ្វីកើតឡើងសោះ ៗ នេះជាភស្តុតាងបង្ហាញឲ្យជនបរទេសគេយល់ឃើញភ្លាមថា ប្រទេសខ្មែរខ្សត់ខ្សោយខាងឧស្សាហកម្មណាស់ ៗ ដូច្នេះហើយបានជាប្រទេសខ្មែរយើងពុំសូវមានកម្មករ-ជនឯកទេសទំងវិស្វករទេ ។ ការខ្វះខាត

សំខាន់នៅត្រង់ចំណុចនេះ គឺមិនមែនមកពីយុវជនខ្មែរជាន់មុនមិនស្រឡាញ់ មិនចូលចិត្តរៀនវិជ្ជាបច្ចេកទេសឬក៏ប្រជាជនខ្មែរល្ងង់ខ្លៅ គ្មានប្រាជ្ញាទឹងសក្ក នោះទេ គឺពិតជានយោបាយដ៏លាមកនៃពួកអាណានិគមបុនប្រទេស អកើរព្រៀ កិច្ចកលទុច្ចាយបន្ទោកបន្ទាបមុខងារបច្ចេកទេស ដើម្បីកុំឲ្យយុវជនខ្មែរ ចាប់អារម្មណ៍ចាប់ចិត្តស្រឡាញ់ចង់សិក្សាជំរៅវិជ្ជានេះ ។ គម្រង់ជិត១០០ឆ្នាំ នៅក្រោមទឹមដែកអាណានិគមនិយម ប្រទេសខ្មែរមានវិស្វករតែពីរនាក់គត់ ។ វិស្វករពីរនាក់សម្រាប់បំពេញកិច្ចការបំពោះស្រុកទាំងមូល ដើម្បីនឹងឲ្យប្រជាជនខ្មែរមានជីវភាពក្ទង់ក្ទួសទៀង ត្រូវឲ្យអស់សំណើចបន្តិចទៅចុះ ។ យើងសុំលុះកុំអត្ថាធិប្បាយតទៅទៀតត្រង់ចំណុចនេះ ។

ឥឡូវដោយប្រទេសបានឯករាជ្យហើយ ។ ដើម្បីនឹងជួសជុលគុណវិបត្តិនេះ យុវជនខ្មែរត្រូវបោះបង់គំនិត« ងារមុខបុណ្យសក្តិ » ចោលចេញ ហើយបង្វែរស្មារតីបន្ទោះទៅកាន់នូវការងារតិកនិកវិញ ព្រោះជាមុខការមានអនាគត ជួយអនុគ្រោះដល់ប្រទេសជាតិ ។

សេដ្ឋកិច្ចប្រទេសយើង បច្ចុប្បន្ននេះពឹងផ្អែកទៅលើកសិកម្មសុទ្ធ ៗ ឯចំណែកកសិកម្មនេះទៀត ក៏នៅទន់ថយណាស់ដែរ គឺមិនសូវបានផលឲ្យ

បានគ្រប់គ្រាន់ប៉ុន្មានទេ ។ រីឯឧស្សាហកម្ម គឺទទេស្អាតគ្មានរោងចក្រអ្វីមួយសោះ ។

បច្ចុប្បន្នកាលនេះ ពេញជាកាលៈទេសៈ ដែលប្រទេសខ្មែរត្រូវចាប់កសាងឧស្សាហកម្ម ។ ដើម្បីកសាងឧស្សាហកម្ម ត្រូវស្ថាបនារោងចក្រ បានរោងចក្រត្រូវការបុគ្គលិកដូចជាកម្មករ-ជនឯកទេស-វិស្វករ ជាដើម ។

ងាកមើលមកប្រទេសយើងលើចំណុចដ៏សំខាន់នេះ យើងមានគុណវិបត្តិមួយធំ ។ តិកនិកជនមានស្តួចស្តើងណាស់ អ្នកជំនាញការគ្មានសឹងតែសោះ ។ ការខ្វះខាតនៃបុគ្គលិកតិកនិករបស់ប្រទេសយើងបង្កើតបញ្ហាមួយធ្ងន់សំខាន់នៅក្នុងព្រំដែន នៃឧស្សាហកម្ម ។ យើងត្រូវឲ្យយល់ច្បាស់ថាបើគ្មានតិកនិក គឺមិនអាចមានឧស្សាហកម្មទេ ។

ការបង្កើតឲ្យមានក្របខណ្ឌតិកនិក ដើម្បីជួយផ្តល់បុគ្គលិកជំនាញនៅផ្នែកឧស្សាហកម្មជាការចាំបាច់នៅក្នុងពេល ដែលយើងចាប់កសាងប្រទេសជាតិ ។ បញ្ហានេះជាបញ្ហាបន្ទាន់ដែលប្រទេសយើងគប្បីយកមកដោះស្រាយឲ្យទាន់ពេលវេលា ដើម្បីកុំឲ្យអាក់ខាន ដល់ដំណើរសេដ្ឋកិច្ច ។

គុណវិបត្តិដ៏សំខាន់នេះអាចដោះស្រាយទៅ បានងាយស្រួលលុះត្រាតែ

យុវជនខ្មែរក្នុងពេលឥឡូវនេះ បែរមករកសិក្សាមុខងារតិកនិកឲ្យបានចំនួនច្រើន ៗ ការពង្រីកក្របខណ្ឌតិកនិកត្រូវការពេលសិក្សាយ៉ាងហោចណាស់ពីរឆ្នាំដែរដើម្បីឲ្យមានសញ្ញាណគ្រប់គ្រាន់មុននឹងទៅធ្វើការនៅក្នុងរោងចក្រ ៗ

នៅប្រទេសខ្មែរផ្នែកខាងតិកនិកនិមួយ ៗ បានចំយកចិត្តទុកដាក់ណាស់ដែរនៅលើការបង្កើតឲ្យមានក្របខណ្ឌតិកនិកជនដូចជា៖ នៅក្រុមអាយស្វ័យយាន ក្រុមសាធារណការ ក្រុមកសិកម្ម-ក្រុមសុខាភិបាលអនុវិទ្យាល័យតិកនិក ៗ ល ៗ

មួយឆ្នាំ ៗ គេឃើញយុវជនខ្មែរ មានវិញ្ញាបនបត្រចំនួនស្តួចស្តើងណាស់ចេញពីសាលានោះ ។ បើគេសង្កេតមួយភ្លែត គេឃើញថាយុវជនខ្មែរយើងមិនសូវស្រឡាញ់សង្វាតសូត្ររៀនវិជ្ជាតិកនិកទេ ។ គុណវិបត្តិនេះបានបង្ហាញឲ្យឃើញជាក់ស្តែង នៅក្នុងរោងចក្ររោងការផ្សេង ៗ គេពុំសូវឃើញមានកម្មករបុគ្គលឯកទេសជាខ្មែរយើងសោះ ។ ផ្ទុយទៅវិញគេប្រទះឃើញសុទ្ធតែកម្មករបរទេស ចំនួនច្រើនធ្វើការនៅទីនោះ ៗ ការណ៍ដែលកើតមានឡើងផ្ទុយយ៉ាងនេះ ធ្វើឲ្យយើងចាប់អារម្មណ៍នឹកទៅដល់អនាគតរបស់ប្រទេសយើងពេក ៗ

នៅប្រទេសបារាំងដែលជាប្រទេសមួយ ក្នុងទ្វីបអឺរ៉ុបល្បីល្បាញមានកិត្តិនាមខ្ពង់ខ្ពស់ខាងវិទ្យាសាស្ត្រពីយូរយារណាស់មកហើយ សព្វថ្ងៃ

នេះប្រទេសយើងនៅខ្វះតិកនិកជននិងវិស្វករច្រើនណាស់ ។ មួយឆ្នាំៗផ្នែកឧស្សាហកម្មត្រូវការ ១០ ០០០ នាក់ (តិកនិកជននិងវិស្វករ) ។ សាលានៅស្រុកបារាំងចាប់តាំងពីសាលាតិកនិក រហូតទៅដល់សាលាតិកនិកជាន់ខ្ពស់ បង្កើតតិកនិកជននិងវិស្វករបានតែ ៤.០០០នាក់ទេ ក្នុងមួយឆ្នាំ ម្ល៉ោះហើយសព្វថ្ងៃនេះ ស្រុកបារាំងមានគុណវិបត្តិមួយធំនៅលើបញ្ហានៃការបង្កើតក្របខណ្ឌតិកនិក ។ នៅប្រទេសបារាំង អ្នកមានលីស្សង់ខាងច្បាប់ពិបាករកការធ្វើជាងកម្មករជំនាញ១០ស្ទួន ហើយបៀវត្សក៏អន់ថយជាងកម្មករទៀត ។

នេះជាឧទាហរណ៍ជាក់ស្តែងបង្អួលឲ្យយើងឃើញច្បាស់កិត្តិយស នឹងតម្លៃដ៏-ប្រសើរនៃមុខការតិកនិកចំពោះសេដ្ឋកិច្ចនិងប្រទេសជាតិ ។

ដូច្នេះយុវជនខ្មែរក្នុងសម័យឯករាជ្យ ត្រូវកាក់ព្រួកយល់ឲ្យច្បាស់នូវអត្ថ-ប្រយោជន៍ដ៏ខ្ពង់ខ្ពស់នៃវិជ្ជាសាស្ត្រតិកនិក ។ គឺវិជ្ជាសាស្ត្រនេះហើយដែលប្រទេសខ្មែរយើងសព្វថ្ងៃកំពុងត្រូវការជាដាច់ខាត ដើម្បីនឹងកសាងសេដ្ឋកិច្ចជាតិយើង ។ ឯករាជ្យភាពយើង អធិបតេយ្យភាពយើង អាចថិតថេរគង់វង់នៅបាន លុះត្រាតែយើងដោះស្រាយគុណវិបត្តិនេះដោយរួសរាន់ ។ បញ្ហានេះអាចនឹងដោះស្រាយបានស្រួល លុះត្រាតែយុវជន

ខ្មែរចេះស្រឡាញ់ចូលចិត្តមុខងារតិកនិកនិងវិទ្យាសាស្ត្រ ។ ចូរយើងជឿជាក់ថា ប្រទេសយើងមិនមែនរស់ មិនមែនធំដោយសារពួកអ្នករាជការប៉ុណ្ណោះទេ គឺពិតដោយសារកម្មករ-កសិករ និងតិកនិកជនបង្កើនផលិតកម្មទាំងឡាយ ។

---

## បាទបាន មានអី

–ក្រណាត់នេះល្អ ដូចម្ចាស់ឯងថា ខ្ញុំចង់កាត់ខោអាវបានមួយសំរាប់ ។ ប៉ុន្តែខ្ញុំប្រាប់ឲ្យហើយ បីខែទៀតទើបខ្ញុំបានប្រាក់ឲ្យ ។

–បាទបាន មានអី លោក ។

–បើអីចឹង ថ្ងៃណាអ្នកឯងដេររួច ?

–បាទ បីខែទៀត ។

X

X X

# ពង្សាវតានៃព្រែកជីកស៊ុយអេ

នៅទិសឥសាននៃប្រទេសអេហ្ស៊ីប មានមណ្ឌលបន្ទៀតមួយហៅថា «ជ្រោយស៊ើរកោះស៊ុយអេស» ។ មណ្ឌលនេះជាព្រំនៃទ្វីបអាស៊ី-អាហ្វ្រិក ។ ជ្រោយស៊ើរកោះនេះ មានសមុទ្រក្រហមនៅខាងត្បូង និងសមុទ្រម៉េឌីតែរ៉ាណេ នៅខាងជើង ។ ព្រែកជីកស៊ុយអេស្ថិតនៅលើជ្រោយស៊ើរកោះ ភ្ជាប់សមុទ្រទាំងពីរខាងលើនេះ ។ ព្រែកជីកស៊ុយអេ មានប្រវែង១៧៤គីឡូម៉ែត្រ ទទឹង១៣៥ម៉ែត្រ ។ កប៉ាល់ទម្ងន់ជាង៤៥០០០តោនឆ្លងកាត់បានដោយងាយ ។

មានមនុស្សភាគច្រើនស្មានថាការកសាងព្រែកជីកស៊ុយអេជាដើមគំនិតរបស់បារាំងសែស ។ តែតាមការពិតវិញមិនដូច្នេះទេ ។ តាំងពីបុរាណមកនៅជ្រោយស៊ើរកោះនោះ ប្រជាជនអេហ្ស៊ីបបានធ្វើព្រែកជីកមួយឈ្មោះថាហ្វាល្លូក ។ ព្រែកជីកនេះក៏បានប្រើប្រាស់ជាយូរឆ្នាំណាស់ដែរ តែដោយកន្លែងនោះដីខ្ពបផ្សំនឹងខ្វះការថែរក្សាព្រែកនេះក៏ជិតទៅវិញ ។ ដល់មក

សតវត្សទី១ លោក ណា-ណាមឌិត វិស្វកររបស់រដ្ឋាភិបាលអេហ្ស៊ីបបានបង្កើតផែនការមួយដើម្បីនឹងបើកព្រែកជីកនោះឡើងវិញ ។ ក្រោយមកលោកអនុកុងស៊ុលនៃប្រទេសបារាំងប្រចាំប្រទេសអេហ្ស៊ីប បានស្នើគ្រោងការមួយដោយអនុលោមតាមផែនការរបស់លោកណា-ណាមឌិតមកជូនរដ្ឋាភិបាលអេ-ហ្ស៊ីបៗក៏យល់ព្រម ។ រដ្ឋាភិបាលទាំងពីរក៏បានចុះហត្ថលេខាលើសន្ធិសញ្ញាមួយដើម្បីអនុវត្តន៍គ្រោងការនោះ ។

ព្រែកជីកស៊ុយអេ ក៏បានចាប់ធ្វើឡើង ។ ដោយសារស្នាដៃកម្មករអេហ្ស៊ីប ១០ឆ្នាំក្រោយមក ការជីកព្រែកនេះក៏បានសម្រេច ។ តែកម្មករអេហ្ស៊ីបក៏បានបង់ជីវិតជាច្រើនដែរក្នុងការកសាងនេះ ។ ប្រទេសអេហ្ស៊ីបបានបង់ក្នុងកសាងនេះពាក់កណ្ដាលពលរដ្ឋ ហ៊ុនឲ្យទៅប្រទេសបារាំងក្នុងការអាជីវកម្មព្រែកជីកនេះទៅថ្ងៃមុខ នឹងជីវិតពលរដ្ឋចំនួន ១២ ០០០នាក់ ។ ក្នុង គ.ស. ១៨៧៥ ធៀតឱកាសដែលប្រទេសអេហ្ស៊ីបលំបាកខាងសេដ្ឋ-កិច្ច ប្រទេសអង់គ្លេសទទួលទិញហ៊ុនរបស់ប្រទេសអេហ្ស៊ីបទាំងអស់ គឺពាក់កណ្ដាលហ៊ុន ។ ដូច្នេះក្រុមហ៊ុនព្រែកជីកស៊ុយអេធ្លាក់ទៅលើដៃជាតិបរទេសទាំងអស់ ។ ដល់ គ.ស ១៨៨២ ដើម្បីនឹងធ្វើអាជីវកម្មលើព្រែកជីកនេះឲ្យបានស្រួល អង់គ្លេសបានបង្កើតរឿងហេតុនឹងអេហ្ស៊ីប រួចក៏តាំង

មូលដ្ឋានយោធានៅលើព្រែកជីកនោះ ។ ក្រោយមកទៀត នៅក្នុង គ.ស. ១៩៣៦ អង់គ្លេសបង្ខំឲ្យប្រទេសអេហ្ស៊ីបចុះហត្ថលេខាលើសន្ធិសញ្ញាមួយ ក្នុងរយៈ២០ឆ្នាំ បើកអំណាចឲ្យអង់គ្លេសដាក់ទាហាន ២០.០០០នាក់ យន្ត-ហោះ៤០០គ្រឿងនៅលើព្រែកជីកស៊ុយអេ ។

ប្រជាជនអេហ្ស៊ីបតស៊ូឥតឈប់ឈរ ដើម្បីទឹងឲ្យប្រទេសខ្លួនមានអធិ-បតេយ្យភាព ឯករាជបរិបូណ៌ ។ ក្នុងខែតុលា ឆ្នាំ១៩៥៤ ប្រទេសអង់គ្លេស បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយទីងអេហ្ស៊ីប ចំពោះបញ្ហាព្រែកជីក ស៊ុយអេនេះ ។ តាមសេចក្ដីព្រមព្រៀងនេះ អង់គ្លេសសុខចិត្តដកថយ កង់ទ័ពទាំងឡាយដែលសំចតនៅលើព្រែកជីកក្នុងរយៈ ២០ ខែ ។

នៅថ្ងៃ១៣ខែមិថុនា ឆ្នាំ១៩៥៦ ទាហានអង់គ្លេសបានដកថយអស់ពីដែនដីអេហ្ស៊ីប ។

នៅថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ១៩៥៦ លោកណាសែរប្រធានាធិបតីអេហ្ស៊ីប បានប្រកាសដកហូតក្រុមហ៊ុនព្រែកជីកស៊ុយអេធ្វើជាសម្បត្តិជាតិ ។ ដូច្នេះឯងព្រែកជីកស៊ុយអេ ក៏បានត្រឡប់មកជារបស់ប្រជាជនអេហ្ស៊ីបវិញ ។

X X
X

# បញ្ហាអនាម័យ

## អនាម័យគ្រឿងបរិភោគ

មានពុទ្ធភាសិតមួយសំដែងថា «ឯកនាមកិំ សព្វេសត្តា អាហារឋិតិកា» សត្វក្នុងលោករស់នៅដោយអាស្រ័យអាហារតែម្យ៉ាង ។ អាហារជាគ្រឿងចាំបាច់ សម្រាប់អប់រំមនុស្សឲ្យប្រកបដោយសុខភាពបរិបូណ៌ ។ អាហារច្រើនហួសកំរិតឬមិនគ្រប់គ្រាន់បណ្ដាលឲ្យកើតជម្ងឺ ។ ហេតុដូចម្ដេចបានជាអាហារហួសកំរិតទៅជាកើតជម្ងឺ ?

អាហារហួសកំរិតគឺអាហារដែលច្រើនទូវសាច់តែមួយមុខ ឬ បន្លែតែមួយមុខឬអាហារច្រើនហួសចំនួន ។ រឿងបន្លែនេះបណ្ឌិតជំនាញខាងអាហារកំពុងតែប្រើវិធីពិសោធ ព្រោះមានអ្នកខ្លះមាស្រ័យតែបន្លែសុទ្ធម្ដេចក៏មិនឈឺ តែអ្នកខ្លះបានឲ្យការថា អាហារប្រកបដោយបន្លែមានជាតិ «វីតាមីន» ច្រើន ម៉្លោះហើយជាតិវីតាមីននេះ អាចគាំពារសុខភាពបាន ។ អ្នកខ្លះឲ្យការថា បន្លែសុទ្ធមិនអាចធ្វើមនុស្សឲ្យមានកម្លាំងមានប្រាជ្ញាដូចជាអ្នកអាស្រ័យអាហារដែលមានសាច់ ត្រី ខ្លាញ់លាយជាមួយគ្នាទេ ។ រឿង

នេះពួកបណ្ឌិតអ្នកជំនាញកំពុងតែបន្តសកម្មភាព ។ ស្រុកស្រែសំបូណ៌តែរាស្ត្រខ្មែរក្រ នេះជាបញ្ហាមួយដែលយើងត្រូវដោះស្រាយ ។ តែយើងត្រូវទោះជា បុគ្គលណាទទួលខុសត្រូវអំពីលទ្ធផលអាក្រក់បែបនេះ បើកភ្នែកមើល ត្រចៀកស្តាប់ គំនិតពិចារណា យើងឃើញថាផលប្រយោជន៍ខាងផលិតផលផ្សេង ៗ នៅក្នុងកណ្តាប់ដៃបរទេសស្ទើរតែទាំងអស់ ។ កំហុសនេះមកអំពីបុរាណសម័យ អ្នកដែលជាចៅហ្វាយគេក្តាប់សេដ្ឋកិច្ចនៅផ្ទាល់នឹងដៃគេ ។ រាស្ត្រក្រ ហេតុនេះបានជាមានការទម្លាប់ « អាស្រ័យបាយកុំឲ្យដាច់ពោះស្លាប់ » ។

ទោះជាមានទុជារសយ៉ាងណាក្តីគ្មានក្តី គឺគ្រាន់តែឲ្យមានព្រះមេបូលក្នុងពោះបានហើយ ធ្វើម្តេចកសាងមករកអាក្រក់ ។ អាស្រ័យអាហារមិនគ្រប់គ្រាន់នេះ អាចធ្វើឲ្យសុខភាពទុនថយ កើតជាជម្ងឺបាន ។ ចុះបើប៉ះទៅលើអ្នកជម្ងឺវិញ ធ្វើយថាជម្ងឺត្រូវតែឡើងកំរិត គឺជម្ងឺស្រាលទៅជាធ្ងន់ ទៅជាស្លាប់ ។

អង្ករជាអាហារចម្បងរបស់រាស្ត្រខ្មែរ ខ្វះអង្ករឬអង្ករមិនល្អ អាចឲ្យកើតជម្ងឺបាន ។ យ៉ាងដូច្នេះត្រូវយកពោត សណ្តែក ដំឡូងទៅជួបជាបណ្តោះអាសន្នបាន បើសិនណាជាយើងមានផលិតផលអស់នេះ ។ តែដើម្បីទប់ទីជម្ងឺស្ពឹកត្រូវអាស្រ័យបន្លែដែលរាស្ត្រក្នុងស្រុកដាំកើត បន្លែនេះមានជាតិ

«វីតាមីន» ដែលមានកម្លាំងល្មមនឹងទប់ជម្ងឺស្តឹកកុំឲ្យផ្ទុះចេញបាន ព្រោះជម្ងឺស្តឹកកាលបើកើតឡើងហើយ ត្រូវចំណាយពេលរាប់ខែ ដើម្បីនឹងមើលថែទាំ ថ្នាំកំក្រ កន្លែងពេទ្យក៏ពេញណែន អ្នកជម្ងឺស្តឹកមានអ្វីជាទីពឹង ធ្វើយថា មានតែសេចក្តីពឹងផ្អែកលើរាជរដ្ឋាភិបាល ។ អាហារខ្លះៗទាំងចំនួនខ្លះទាំងជាតិ ត្រូវកើតជម្ងឺស្តឹក ដែលយើងអាចបញ្ចូនទៅក្នុងជម្ងឺសង្គមបាន ព្រោះជម្ងឺស្តឹកនេះអាចចាប់មនុស្សជាចំនួនច្រើន ។ យ៉ាងដូច្នេះគ្រឿងបរិភោគជាគ្រឿងចាំបាច់របស់មនុស្សគ្រប់រូប ។ បន្តពីអង្ករ មានបញ្ហាទឹក ជារឿងមួយយ៉ាងសំខាន់ដែរ ព្រោះទឹកជាមិត្រឬសត្រូវរបស់មនុស្ស ។ យើងត្រូវការទឹកដើម្បីអាស្រ័យសំអាតខ្លួនប្រាណ ដុសលាងសំពត់អាវ ធ្វើស្រែចំការដាំបន្លែ ។ល។ ខ្វះទឹកធ្វើយថាខ្វះអានាម័យ ។ ចុះបើទឹកសម្បូរ យើងស្រែកថា មានអនាម័យបានដែរឬទេ ? ទឹកក្រខ្វក់ជាសម្បុករបស់មេរោគ ។

យើងអាចហ្នូនបានថា ប្រជាជនស្រុកក្រៅរសដោយសារទឹកមិនស្អាត មានគ្រោះថ្នាក់ដោយសារជម្ងឺពោះវៀន ។ ត្រង់រឿងនេះ មាននៅទីកន្លែងខ្លះ ដែលមានកើតជម្ងឺក្តៅស ទប់សន្ទិនរោគពោះវៀនដែលបារាំងហៅថា «ថៃហ្វូទីហ្វ៊ិត» ហើយប្រជាជនបន្ទោរបង់ពាសវាល ពាសកាល មាន

ការស្លាប់បន្ត ៗ គ្នាព្រោះមានជម្ងឺដោយទឹកនឹងចំណីអាហារ ស្លាប់បែបនេះមិនគួរជាឲ្យស្លាប់សោះ នេះជម្ងឺវាមកកាត់អាយុតែម្ដង ហើយយើងអាចជៀសវាងដោយប្រើបន្ដន់តាមអនាម័យគ្រប់ម្ហូបអាហារកុំឲ្យរុយរោមនឹងប្រើទឹកស្អាត ៗ ចំពោះរឿងអាហារនេះ មានការទាក់ទងដល់ទៅរឿងកីឡា នឹងរឿងអនាម័យ ក្នុងសាលារៀនដែលខ្ញុំពណ៌នានៅខាងក្រោមនេះតទៅ;

## ១ – ៣ អនាម័យកីឡា

កីឡាត្រូវការអ្វី ? សមត្ថភាពកាយជាកម្លាំងរបស់កីឡាជាកិត្តិយសកីឡាជាតិ ៗ យ៉ាងដូច្នេះក្រុមកីឡា ត្រូវមានគ្រូពេទ្យអ្នកទទួលការក្នុងការអប់រំកាយ បើគ្មានគ្រូពេទ្យសម្រាប់កីឡា អ្នកចូលទៅប្រកួតប្រណាំងក្នុងការកីឡា ឃើញថាមានគ្រោះថ្នាក់ដល់កាយជាមិនខាន ៗ អ្នកដែលស្នេហាកីឡាមិនអាចនឹងដឹងថាខ្លួនលេងកីឡាបានឬមិនបាននោះឡើយ បេះតែចូលលេងតាមចិត្តចង់ អ្នកដែលទទួលឲ្យលេងបេះតែទទួលឲ្យបានចំនួនច្រើន ដើម្បីជ្រើសរើសរកជើងឯក ៗ ហេតុនេះបុគ្គលអ្នកចង់ នឹងបុគ្គលដែលទទួលឲ្យលេង ដោយគ្មានសំបុត្រអនុញ្ញាតពីពេទ្យបានប្រព្រឹត្តអំពើលោកលើរូបរាងកាយរបស់ខ្លួន នឹងបំភ័ន្តលើរូបរាងកាយអ្នកដទៃ ៗ តែអំពើ

នេះ សុទ្ធតែធ្វើដោយគ្មានចេតនាឡើយ ព្រោះមិនបានទឹកក្អក ដល់លទ្ធផលអាក្រក់ដែលអ្នកកីឡាត្រូវទទួលគ្រោះថ្នាក់ ដែលអាចកើតមានឡើងនៅក្នុងរយៈពេលជាច្រើនឆ្នាំក៏មាន ម្ល៉ោះហើយទៅចោទប្រកាន់លើជម្ងឺផ្សេង ៗ ក្រៅអំពីហេតុដែលកើតអំពីកីឡា ខ្ញុំសង្កេតឃើញថា អ្នកកីឡាខ្មែរ លេងកីឡាពឹងផ្អែកទៅលើកម្លាំងកាយនឹងកម្លាំងចិត្ត ហើយមិនចេះថែទាំខ្លួនប្រាណ ៗ ដែលឈ្មោះថាមិនចេះថែទាំខ្លួនប្រាណនោះ មានន័យបែបណា ? គឺហាត់មិនសូវមានរបៀបប្រើកម្លាំងមិនចេះប្រមាណ ម្ហូបអាហារមិនចេះរើសមុខ គិតតែឲ្យឆ្ងាញ់ឲ្យផ្អែត ធំបំផុតមិនចេះថ្នមខ្លួនដោយប្រព្រឹត្តស្រា, ស្រី, ល្បែងស៊ីសង ដែលជាអំពើធ្វើឲ្យអ្នកនោះឆាប់អន់ខ្សោយកម្លាំង ៗ

យូរៗទៅអ្នកកីឡាខ្មែរយកចិត្តជាធំ ដើម្បីលេងកីឡា ចំណុចត្រង់នេះខ្ញុំសូមបញ្ជាក់ថា ក្នុងកីឡានេះគេមិនគ្រាន់តែប្រើកម្លាំងកាយតែមួយមុខ គឺត្រូវប្រើគំនិតប្រាជ្ញាមកជួយផង កាយមានជម្ងឺប្រាជ្ញាត្រូវអន់ ចិត្តក៏ពុំសូវខ្លាំងពូកែដែរ ម្ល៉ោះហើយជ័យជំនះបើបានក៏បានដោយលំបាក ៗ បញ្ហាកីឡានេះជាបញ្ហាពិបាកជាទីបំផុត ព្រោះដើម្បីអប់រំកីឡាឲ្យមានកិត្តិយស មានដំណើរទាន់សម័យដូចជាប្រទេសនានា ក្រុមកីឡាត្រូវការប្រាក់ផ្ទាល់ខ្លួន និងឲ្យមានស្ទាន់ដោយសទ្ធាពីឯកជនផង ៗ

ដូចជាប្រទេសធំ ៗ អ្នកលេងកីឡាមិនមែនដុនដាបដូចជានៅស្រុកខ្មែរយើងទេ អ្នកប្រដាល់ អ្នកទាត់បាល់ អ្នករត់ប្រណាំង ។ល។ មានតម្លៃដូចជាពេជ្រទាំងគ្រាប់ គឺមិនគ្រាន់តែអ្នកជំនួញធំ ៗ ជួយអប់រំតែប៉ុណ្ណោះទេ មានទាំងជាតិផងទេ ដណ្ដើមគ្នាទិញសម្រាប់ទុកប្រើការក្នុងកីឡារបស់គេទៀត ហ៊ានដល់ទៅដេញថ្លៃគ្នា ដូចជាដេញថ្លៃទិញដីឬព្រែក ។ យ៉ាងដូច្នេះអ្នកលេងកីឡាម្ដេចក៏មិនប្រឹង ម្ដេចក៏មិនថែទាំខ្លួន ព្រោះនៅប្រទេសធំ ៗ កីឡាអាចមានកម្លាំងសម្រាប់ចិញ្ចឹមជីវិតអ្នកលេងបាន បំណែកឯកីឡាយើងវិញ គិតតែមួយបំអែត ដល់លេងយូរ ៗ ទៅ ប្រពន្ធដុកដាន់បន្តិច ដោយជម្ងឺមករួបរិតបន្តិចដោយអស់កម្លាំងបន្តិច បុគ្គលនោះឯងត្រូវតែផ្លាស់របបថ្មី បើយ៉ាងដូច្នេះកិត្តិនាមជាតិផ្នែកកីឡានឹងមានជីវិតរស់នៅឯណាបាន អ្នកខ្លះព្យែកបានតែ២·៣ឆ្នាំ បាត់ឈ្មោះសូន្យទៅ ៗ ដូច្នោះដើម្បីឲ្យកីឡាមានសន្ទុះទាន់សម័យ ដូចជាប្រទេសនានាត្រូវឲ្យមានអនាម័យ ដែលជាគ្រឿងចាំបាច់ នឹងឲ្យមានវិន័យយ៉ាងតឹងតែងចំពោះអ្នកលេងកីឡា បើមិនដូច្នោះទេកីឡាខ្មែរមុខតែមានកេរ្តិ៍ឈ្មោះក្បិបក្បុតដូចជាផ្លុកបន្ទោរ ។

## ១៤-អនាម័យសាលារៀន

និស្សិតគឺអ្វី? និស្សិតជាគ្រឿងសង្ឃឹមនៃវាសនាអនាគតរបស់ជាតិ ។

នៅក្នុងប្រទេសខ្លះដែលប្រកបដោយអារ្យធម៌ ដ៏ជ្រៅជ្រះ គេលែងប្រើហើយ ពាក្យថាកូនសិស្សខ្ជិល» ព្រោះតាមការពិសោធរបស់គេៗថាកូនសិស្សមិនខ្ជិល ដោយឯងៗទេ គឺមានហេតុអ្វីមួយបណ្ដាលឲ្យកូនសិស្សនេះខ្ជិល ។ កូនសិស្សខ្ជិលមកអំពីហេតុពីរយ៉ាង (ខ្ញុំនិយាយដោយសង្ខេបទៅចុះ ។

ទី១-ដោយមានហេតុក្នុងគ្រួសារមានខ្វះការអប់រំនឹងការ ទាស់ទែងគ្នា ។

ទី២-ដោយជម្ងឺ កូនសិស្សមានជម្ងឺជាកូនសិស្ស មិនចូលចិត្តក្នុងការរៀនសូត្រ ព្រោះវារវល់តែប្រើកម្លាំងកាយដើម្បីតស៊ូនឹងកម្លាំងជ្រៅជ្រៃរបស់ជម្ងឺ ។ សៀវភៅជាសត្រូវ សាលាជាទីកន្លែងពិបាកដកដង្ហើម ទោះជាគ្រូទោសក៏ដោយ ខ្វាតបានលេខក៏ដោយ នៅតែមានការព្រងើយកន្តើយក្នុងការរៀនសូត្រជានិច្ច ។ យូរៗ ទៅដល់បានពិន្ទុសូន្យច្រើនពេកទៅជាកំផ្លូងលេងថា «បានពងមាន់ច្រើនទុកស្ងោរស៊ី» ។ ជម្ងឺមិនគ្រាន់តែធ្វើឲ្យកូនសិស្សខ្ជិលតែប៉ុណ្ណោះទេ គឺធ្វើឲ្យអន់ប្រាជ្ញាទឹនឆាប់ភ្លេចរៀន ដូចជាមានដុះសាច់ក្នុងប្រមុះ ឬក្នុងកជាដើម ។ ទន្ទេញមិនសូវចាំ មិនសូវមានវ័យបរិបូរណ៍ ។ នេះហើយយូរៗទៅ ជាគូកននឹងការខ្ជិល ។ មិនបន្តិចបន្តួចខ្ជិលទាល់តែខ្ជប់សៀវភៅ ខ្ជិលយកសៀវភៅមកមើល ទាល់តែងងុយដេក ខ្ជិលយកដងប៉ាកកាមកសរសេរ ធ្លាក់ពីដៃមិនដឹងខ្លួនដេក

ជ្រប់លើតុ ស្រមុកខ ។ តែបើពៅជាសាកប្ចាពីរឿងឥតប្រយោជន៍វិញ ខ្ជិលរត់បាត់បេញពីខ្លួនអស់ ។ ដោះស្រាយបញ្ហាកូនសិស្សខ្ជិល គឺដោះស្រាយសុខភាពរបស់កូនសិស្ស ដោះស្រាយរបៀបបង្រៀន ។ ម្ដេចដែលហៅថាបញ្ហាសុខភាពរបស់កូនសិស្សនៅក្នុងសាលារៀន? ។ ពេទ្យមិនគ្រាន់តែមានការៈក្នុងការមើលជម្ងឺតែមួយមុខទេ គឺមានមុខការស៊ើបអង្កេតរកជម្ងឺបិទមុខដែលរាថតនៅក្នុងរូបកាយកូនសិស្ស ។ ជម្ងឺបិទមុខនេះហើយដែលអាចបំបាត់បាន កាលបើវានៅថ្មី ៗ ។ រួចអំពីជម្ងឺបិទមុខ កូនសិស្សដែលមានសុខភាពល្អត្រូវចាត់វិធានការកុំឲ្យសុខភាពនោះទន់ខ្សោយទៅវិញ ។ ក្នុងថ្នាក់នីមួយ ៗ មិនត្រូវឲ្យមានកូនសិស្សហួសចំនួន បញ្ហានេះពិបាកណាស់ ដោយកូនសិស្សមានចំនួនហួសវិស័យ កូនសិស្សហួសចំនួនតើមានលទ្ធផលអាក្រក់បែបណា? ។

១១–លោកគ្រូបង្រៀនមិនអាចរកការចំរើនក្នុងការបង្រៀនបានឡើយ ។

១២– កូនសិស្សខ្វះខ្យល់ដកដង្ហើមអន្ទុយប្រជ្រៀតគ្នា អក្សរដែលសរសេរនៅក្ដារខៀនក៏មើលមិនសូវឃើញច្បាស់ ជាហេតុបណ្ដាលឲ្យឆាប់ខូចភ្នែក ។ កូនសិស្សច្រើនជាហេតុមួយធ្វើឲ្យកូនសិស្សងាយប្រឡែងជជែកគ្នា លោកគ្រូត្រូវតែពិបាកចិត្ត ។

ថ្នាក់នីមួយ ៗ ត្រូវឲ្យធំទូលាយប្រកបដោយទ្វារបង្អួចគ្រប់គ្រាន់ ដំបូលប្រក់ឲ្យជិតមានពន្លឺនៅពេលដែលមេឃស្រទំ ឬពេលភ្លៀង ។ រឿងថ្នាក់នេះ បើត្រូវងងិតមើលអក្សរមិនឃើញក្នុងពេលមេឃស្រទំ ពពកខ្មៅ កូនសិស្សរង៉ោរណ្តំផ្គាម ត្រូវទឹកភ្លៀងឃើញថាសុខភាពរបស់កូនសិស្សនឹងត្រូវក៏អន់ថយដែរ, ការរៀនសូត្រក៏វិនាស លិចឯការតស៊ូនឹងជម្ង ជាតិវិញ ។

នៅក្នុងសាលា ត្រូវមានទឹកស្អាតសំរាប់ឲ្យកូនសិស្សអាស្រ័យ នឹងដុសលាងដៃ មានទីលានសំរាប់ហាត់ប្រាណ, មានបង្គន់គ្រប់គ្រាន់, បើមានកូនសិស្សភេទទាំងពីររៀនជាមួយគ្នា តោងធ្វើបង្គន់ឲ្យដាច់ដោយឡែកពីគ្នា ។

នៅក្រៅសាលាខ្ញុំប្រទះឃើញកូនសិស្សតូចៗខ្លះដើររាប់គីឡូ កណ្ដាលថ្ងៃត្រង់ឬភ្លៀងមក ឃើញគួរឲ្យសង្វេក ទូរវាសនារបស់កុមារអស់នេះណាស់ ។ បើដើរឆ្ងាយម្ល៉ឹងៗ តើនឹងមានកម្លាំងឯណានឹងរៀនសូត្រឲ្យបានស្រួលនឹងគេ ។ ក្នុងរឿងនេះ គួរឲ្យមានបង្កើតអង្គការសង្គ្រោះដល់កុមារទុគ៌ត ដោយរកឡានដឹកនាំកុមារអស់នេះមកសាលារៀន ។

អង្គការសង្គ្រោះកុមារទុគ៌ត អាចធ្វើដោយកម្លាំងរាជការ ដោយ

កម្លាំងជនរួមជាតិឬបញ្ចូលកងអង្គការតែមួយក៏បាន ។ រឿងនេះខ្ញុំគ្រាន់តែប្រកាសជូនអស់លោក, ប្រជាជនជាយោបល់ ឯការសម្រេចសូមផ្ទេរទៅលើស្មារតីស្នេហាជាតិ នឹងចិត្តសទ្ធារបស់បុគ្គលម្នាក់ៗ ។

## ១៥ អនាម័យបារិក

ចិត្តគំនិតល្អឬអាក្រក់ មានមូលហេតុគឺកាយគ្មានជម្ងឺ ឬមានដំរេះវិជ្ជា នឹងការអប់រំក្នុងសង្គម ។ សព្វថ្ងៃនេះនៅក្នុងពេទ្យវិបត្តិចរិតនៅតាមខ្មៅ; គេសង្កេតឃើញថាស្រាទឹងកាមរោគជាមេរបស់ជម្ងឺឆ្កួត ។ បញ្ហាខាងផ្លូវចរិតនេះមានតែបណ្ឌិត ស៊ុគ·ម៉ម ទេដែលលោកជំនាញខាងផ្លូវនេះ ។ ខ្ញុំបានដំរាបពីខាងលើមកហើយថា ជម្ងឺជាគ្រឿងទុបសគ្គលើកាយលើចិត្តវាចាដូចសុភាសិតបារាំងមួយថា«ចិត្តបរិសុទ្ធអាចស្ថិតនៅក្នុងកាយណាដែលបរិសុទ្ធដែរ»

កាយបរិសុទ្ធហើយ បើមានដំរេះវិជ្ជាមុតមាំ តើដំរេះវិជ្ជានោះសំរេចបានថា ជម្ងឺជាប្រយោជន៍ដល់ជាតិជាជាចំខាតបានដែរឬទេ? ដំរេះវិជ្ជាជាអាវុធ បើអ្នកនោះឯងមិនចេះប្រើដំរេះវិជ្ជានេះ អាចប្រែទៅជាសត្រូវនឹងជាតិកំណើតខ្លួនវិញបាន បណ្ដាលមកអំពីខ្វះការអប់រំនូវចិត្ត ។ គ្រឿងបមុខដែលសម្រាប់អប់រំចិត្តនេះគឺ ៖

១– សៀវភៅ - កាសែត

២- កុន-ល្ខោន

៣ មជ្ឈដ្ឋានសង្គមនឹងការរស់នៅក្នុងសង្គម សៀវភៅ - កាសែត

កុន - ល្ខោន មានកម្លាំងដូចជាអាភៀន តែប្រព្រឹត្តជាប់មុខជាញៀនលែងមិនងាយរួចទេ ព្រោះវាអាចផ្តិតជាប់នៅក្នុងគំនិតនៃអ្នកមើល ៗ បើគ្រឿងអស់នេះបង្ហាញតែអំពើពុករលួយហើយ គំនិតចិត្តសំដីវាពុករលួយតាមហ្នឹងដែរ ព្រោះមនុស្សគ្រប់រូបចូលចិត្តណាស់ធ្វើត្រាប់គេ បើមានការអ្វីប្លែកមិនដែលមាន មនុស្សត្រូវការប្រជែងប្រណាំងគ្នាយកមុនគេជាដរាបៗ បើរបស់ប្លែកនេះវាល្អក៏គាប់ប្រសើរ បើបែរជាអាក្រក់វិញវាឆ្លងគ្នាដូចជាជម្ងឺអំបល់ ៗ ពាក្យថាអនាម័យនៅក្នុងអត្ថបទនេះ ប្រែថាវិធីការពារនូវចិត្តនេះហើយជាបញ្ហាការសម្រាប់ប្រើកាយរបស់យើងឲ្យប្រព្រឹត្តការល្អ ឬ អាក្រក់ ហេតុនេះ ទោះជាកាយបរិសុទ្ធល្អយ៉ាងណាក៏ដោយ បើមានជម្ងឺចិត្តហើយ ចិត្តវាមុខតែនាំកាយឲ្យមានជម្ងឺដូចវាជាមិនខាន ៗ

មជ្ឈដ្ឋានសង្គមនឹងការរស់នៅរបស់សង្គម ជាគ្រឿងមួយយ៉ាងសំខាន់ណាស់ក្នុងការទាញចិត្តមនុស្ស ឲ្យឈានទៅកាន់សេចក្តីចំរើនថ្លៃថ្នូរ ឬច្រានឲ្យចុះទៅក្នុងរណ្តៅស្អុយរលួយថោកទាប ៗ យ៉ាងដូចនេះសៀវភៅ

កាសែត ហ្គោនកុន មជ្ឈដ្ឋានសង្គមទីងការរស់នៅក្នុងសង្គម ជាគ្រឿងចាំបាច់សម្រាប់អប់រំចិត្តនៃជាតិទាំងមូល ។

---

## ផ្កាយទៅ

—មានអ្នក អញ់ទាល់ពេកទៅ ចង់រកលុយទិញថ្នាំមួយមិនបានផង ។

—បើដូច្នេះ ឯងប្រហែលជាវេទនាណាស់ទៅ ។

—ទេ! មិនជាណាស់ណាទេ ព្រោះអីអញមិនចេះជក់ថ្នាំផ្លង ។

X

X X

# យុវជនខ្មែរ និងលោកជូ-អេង ឡាយ

ក្នុងដំណើរទស្សនាការរបស់លោក ជូ-អេន ឡាយ មកប្រទេសខ្មែរ យុវជនយើងបានខ្នះខ្នែងរៀបចំទទួលលោកដោយសមរម្យ យើងសូមបញ្ជាក់ថា យុវជនខ្មែរដែលទទួលលោក ជូ-អេង-ឡាយ មិនមែនទទួលលោកក្នុងឋានៈជាតំណាងគណៈបក្សកុម្មុយនិស្ត ឬជាអង្គការនយោបាយ ណាមួយទេ យើងទទួលនេះ គឺទទួលតំណាង បន្ទុកភាពនឹងតំណាងយុវជនចិន ។

នៅថ្ងៃ ២៦ វិច្ឆិកា ពេលម៉ោង ៩ សាលាវិទ្យាល័យស៊ីសុវត្ថិ យុវជនខ្មែរបានមកកុះករដើម្បីនឹងទទួលលោក ជូ-អេន-ឡាយ ។ ក្នុងទីធ្លាវិទ្យាល័យ គេឃើញមានសិស្សានុសិស្សប្រដាប់ដោយសំលៀកបំពាក់តាមសាលា ឈរត្រៀបត្រាចាំលោក ជូ-អេន ឡាយ ។ សិស្សនៃអនុវិទ្យាល័យនារីនរោត្តម ឈរជាជួរប្រឡបជិតសិស្សនៃសាលាគរុវិជ្ជា ។ ក្រៅពីនោះឃើញមានឯកជនជាច្រើនទៅប្រុងចាំមើល ។ ក្នុងបរិយាកាសដ៏រីករាយនេះ គេនឹកស្មានថា គួរណាស់តែសាលាធំ ៗ នៅក្រុងភ្នំពេញទាំងប៉ុន្មាន មានសមាគមគ្រប់ ៗ សាលាទៀត ។ ព្រោះគេឃើញក្រៅពីសិស្សនៃវិទ្យាល័យ អនុវិទ្យាល័យ

នារីទីនិសាលាគរុវិជ្ជា មានសិស្សសាលាឯទៀតដែរតែមកជាឯកជន ពុំមានតំណាងអ្វីទេ ។ តែយើងអាចសន្និដ្ឋានបានថា ក្នុងពេលឥឡូវនេះចំពោះការខ្វះខាតខាងអង្គការចាត់តាំងក្នុងបរិស្ស យុវជនដែលមកជួបជុំនៅពេលនេះជាតំណាងយុវជនខ្មែរទាំងមូល ។

ម្យ៉ាងដោយសាលាធំៗនៅស្រុកខ្មែរ គឺវិទ្យាល័យស៊ីសុវត្ថិ អនុវិទ្យាល័យនារីទីនិសាលាគរុវិជ្ជា ម្យ៉ាងទៀត យុវជនខ្មែរទាំងមូលមិនថាស្រុកស្រែស្រុកក្រុងស្រឡាញ់សន្តិភាព យុវជនខ្ពើមសង្គ្រាម ខ្ពើមការបំបែកបំបាក់សាមគ្គីស្រឡាញ់ការស្ងប់ស្ងាត់ដើម្បីរៀនសូត្រ ។

ដូចក្នុងសុន្ទរកថារបស់តំណាងយុវជនខ្មែរបានបញ្ជាក់ ដែលយើងនឹងចុះជូនទាំងស្រុងខាងក្រោយនេះ យុវជនខ្មែរទទួលលោក ជូ-អេន-ឡាយ ក្នុងឋានៈជាតំណាងបញ្ចសីលា តំណាងសន្តិភាពនិងតំណាងយុវជនចិន ។

ក្រោមការជិះជាន់នៃអាណានិគមនិយមជិតមួយសតវត្ស យុវជនខ្មែរបានស្គាល់ទុក្ខគ្រប់សព្វក្នុងការស្វែងរកចំណេះវិជ្ជា ស្គាល់លំបាកនៅពេលអសន្តិសុខវឹកវរចលាចល ។ ហេតុនេះហើយបានជាយុវជនខ្មែរស្រឡាញ់សន្តិភាព ខ្ពើមសង្គ្រាម ហើយស្រឡាញ់នេះទៀត គឺស្រឡាញ់ដោយ

យល់ច្បាស់ មិនមែនស្រឡាញ់សន្តិភាពតាមមនោសញ្ចេតនាអណ្តែតអណ្តូងទេ ។

អកប្បកិរិយាស្រឡាញ់សន្តិភាពបានបញ្ចេញឲ្យឃើញច្បាស់ នូវពេលដែលលោក ជូ.អេន ឡាយ គណៈប្រតិភូចិនអញ្ជើញមកដល់ ។ ពេលនោះគេឮតែសម្រែក ជយោ ! លោក ជូ.អេន.ឡាយ ! ជយោ ! សម្តេចព្រះឧប.យុវរាជ ជយោ ! មិត្តភាពខ្មែរ.ចិន ! ជយោ ! សន្តិភាព ! ។ ក្រោយពេលដែលតំណាងយុវជនខ្មែរបានសូត្រសុន្ទរកថា សំដែងទឹកចិត្តមេត្រីភាពចំពោះគណៈប្រតិភូចិន លោក ជូ.អេន-ឡាយ បានឆ្លើយតបមកវិញ ដោយបង្ហាញអនាគតស្រុកនិមួយ ។ នៅលើដៃយុវជន ។ លោកបានលើកឧទាហរណ៍ យុវជនចិន ក្នុងពេលដណ្តើមយកសន្តិភាព ក្នុងការស្តាបនាស្រុកឡើងវិញ ទាំងក្នុងអនាគតរបស់ស្រុក ។ លោកបានបង្ហាញជាំទៀតនូវការបច្ចេកទេសក្នុងការកសាងស្រុក ។ ពាក្យនេះសម្តេចព្រះឧប-យុវរាជយើងបានរំលឹកយើងជារឿយ ៗមកដែរ ហើយលោកជូ.អេន-ឡាយ បានបញ្ជាក់ថែមទៀត ដោយបង្ហាញការជាក់ស្តែងនៅប្រទេសចិន ។ គួរតែយុវជនយើងយកពាក្យសំដីអស់នេះមកពិចារណាឲ្យហ្មត់ចត់ ហើយបែរទៅរកវិជ្ជាបច្ចេកទេសឲ្យច្រើន បើយើងចង់ឲ្យស្រុកយើង នគរយើងរុងរឿងថ្កុំ

*ច្រើនអានអនាគតក្តីស្មាន ។ តមកទៀត យុវជនខ្មែរបានជូនវត្ថុទុកជាអនុស្សាវរីយ៍ ចំពោះយុវជនចិន តាមលោក ជូ អេន ឡាយ ។ ក្រោយមកក្នុងសំណូរនៃសំរែក ជយោ ! លោក ជូ អេន ឡាយ ! ជយោ ! សម្ដេច-ព្រះឧបយុវរាជ ! ជយោ ! សន្តិភាព ! គណៈប្រតិភូចិន បានលាយុវជនខ្មែរ និងធ្វើដំណើរទៅបន្តការតទៅទៀត ។*

---

## ដីទៀតត្រង់ណា ?

មានអ្នកមានម្នាក់ មានលុយចាយមិនអស់ទេ បានពេកទៅៗ ជានិច្ចដឹងធ្វើការអ្វីផ្សេងទៀត ។ តែគាត់មានតណ្ហាមួយ គឺប្រមូល "តែម" ប៉ុស្តិ៍បុរាណចាស់ៗទុក ។ គាត់ប្រមូលតែ តែម ណាដែលរកមិនបាន ។ បើគាត់ឮថា ឯណាមាន តែម ពីបុរាណហើយ ហើយប្លែកពីរបស់គាត់ទៀត គាត់ដេកមិនលក់ បរិភោគមិនបានទេ លុះណាតែគាត់ស្វែងរកបាន ។

ក្នុងការស្វែងរកនេះ គាត់បាន តែម មួយពីបុរាណដែលក្រដាសគេ ។ ហើយនេះ គាត់ដឹងថាមានតែពីរទេ ក្នុងសាកលលោកទាំងមូល ។ ដូច្នោះគាត់តែងតែសុំបងប្អូនគេជួយដើររក ។ ក្រោយមកគាត់បានដឹងថា ម្ចាស់ តែម ដែលនៅសល់នោះនៅឯប្រទេសហូឡង់ គាត់ក៏កាត់មករកភ្លាម រកទាល់តែឃើញម្ចាស់នោះ ។ លុះឃើញកាលណា គាត់ក៏តថ្លៃទិញតែមគេភ្លាម ម្ចាស់តែមក៏សុខចិត្តលក់តែមនោះថ្លៃ ១ លាន ដុល្លា (១០០០០០០) ។ អ្នកមានក៏ទិញភ្លាម ។ ឲ្យលុយគេមិនទាន់ផុតពីដៃផង ក៏ទាញឈើគូសយកមកដុតតែមនោះអួយរំពេច ។ កាលណាតែមឆេះអស់ហើយ គាត់ក៏ញញឹមញញែមហើយថា តាំងពីថ្ងៃនេះទៅគ្មានអ្នកណាមានដូចខ្ញុំទេ ។

# រឿងកំសាន្ត

## ដីធំប៉ុនណា ទើបល្មមចិត្តមនុស្ស

(ប្រែចេញពីរឿងព្រេងរុស្ស៊ី តាមសេចក្ដីទានរបស់លោក

(ទៀងអុង គុលសុយ)

ប៉ាខុមជាអ្នកស្រែរុស្ស៊ីមួយរូប ដែលលោភចង់តែពង្រីកដីភូមិខ្លួន ។ គេប្រាប់គាត់ថា នៅដំបន់រុស្ស៊ីខាងកើត ពួកបាក់ស្គារលក់ដីថោកៗ ។ ប៉ាខុមប្រមែប្រមូលប្រាក់ ហើយធ្វើដំណើរយ៉ាងឆ្ងាយគន្លង ដរាបដល់ស្រុកពួកបាក់ស្គារនោះ ។

.... នាយស្គារស្ហ៊ីណា(១) និយាយប្រាប់ទៅគាត់ថា «យើងលក់ដីគិតតាមទំហំមួយថ្ងៃៗ ។ ឯងដើរព័ទ្ធមួយថ្ងៃបានដីប៉ុនណា ដីនោះនឹងបានឯងប៉ុណ្ណោះ ។ តម្លៃមួយថ្ងៃគិតមួយពាន់រូប» ។

ប៉ាខុមនឹកឆ្ងល់ក្នុងចិត្ត ហើយពោលមាត់ថា: «យី! ក្នុងមួយថ្ងៃគេអាចដើរព័ទ្ធបានដីមិនតិចទេ» នាយស្គារស្ហ៊ីណាក៏អស់សំណើច: «បានប៉ុន

---

១- ណាក្សុរស្ហ៊ី ប្រែថាមេភូមិ ។

ណាក៏ដោយ យើងប្រគល់ឲ្យឯងទាំងអស់ ប៉ុន្តែមានលក្ខណ៍ណាមួយ ។ បើឯងមិនត្រឡប់មកទីដើមវិញទេ ក្នុងមួយថ្ងៃ ប្រាក់ឯងនឹងត្រូវអសារបង់”។

ប៉ាខុមក៏ដណ្តឹងទៅទៀតថា ចុះគិតធ្វើដូចម្តេច ដើម្បីនឹងចារផ្លូវ សំគាល់ផ្លូវដែលខ្ញុំដើរ ។

យើងនឹងទៅឈរកន្លែងណាដែលគាប់ចិត្តឯង ដែលឯងបានជ្រើសរើសជាមុនស្រេច. យើងទៅចាំកន្លែងនោះរហូត ។ ឯចំណែកឯងវិញ ឯងចេញដើរពីទីនោះទៅមួយជុំ ។ កូនប្រុសយើងទាំងប៉ុន្មាននឹងជិះសេះតាមឯង ហើយត្រង់កន្លែងណាដែលឯងបញ្ឈប់ វានឹងបោះបង្គោលឲ្យ ។ រួចហើយទើបយើងយកខ្សែលួសមួយគន្លង ភ្ជាប់បង្គោលមួយទៅបង្គោលមួយ ។ ឯងចង់ដើរបានមួយជុំធំប៉ុនណា ស្រេចនូវចិត្តឯងចុះ ។ ប៉ុន្តែមុននឹងថ្ងៃលិចត្រូវឯងមកដល់ទីដើមវិញ ទំហំដែលឯងក្រសោបបានប៉ុន្មាន នឹងត្រូវបានឯងទាំងអស់ ។

ប៉ាខុមក៏សុខចិត្ត

ស្អែកឡើង គេលើកគ្នាទៅតាំងពីព្រលឹម

នាយស្តារស្ទីណាដោះកន្ទបគាត់ ដែលធ្វើអំពីស្បែកកញ្ជ្រោងហើយដាក់នៅកំពូលភ្នំមួយតូច ។ គាត់ប្រាប់ថា “នេះសំគាល់ជាទីដើម ។ ទុក

កូនឈ្នួលឯងឲ្យចាំនៅទីនេះចុះ ហើយដាក់ប្រាក់ឯងមក ។ ចុះឯងចេញដើរពីនេះទៅ រួចត្រឡប់មកទីនេះវិញ ។ ឯងដើរព័ទ្ធបានប៉ុន្មាន យកប៉ុណ្ណឹងចុះ ។

ប៉ាខុមចេញទៅ ដើរនឹងដំហានល្អណាស់ មិនយឺតមិនលឿន ។ ដើរបានមួយវៀក (២) បង្គាប់ឲ្យគេបោះបង្គោលមួយ ។ រួចហើយដើរហួសទៅទៀត ដល់ជក់ជើងគួរសមហើយ គាត់បន្ថែមឲ្យលឿនបន្តិច ។ លុះដើរឆ្ងាយបានក្រែលហើយ ក៏បង្គាប់ឲ្យគេបោះបង្គោលមួយទៀត ។ ប៉ាខុមងាកមើលក្រោយម្តង ឃើញថ្ងៃចាំងក្តៅខ្លាំង ហើយឃើញមនុស្សទៀតខ្ទាប់នៅលើនោះ ។ ប៉ាខុមប្រមាណឃើញខ្លួនដើរបានប្រាំវៀកហើយ ។ ថ្ងៃកាន់តែក្តៅឡើង គាត់ដោះអាវសន្ទះចេញយកមកក្រវាត់នៅចង្កេះ ហើយស្រូតរូតដំណើរទៅមុខទៀត ។ លុះដើរបានប្រាំវៀកទៀត មេឃក្តៅមែនទែន ប៉ាខុមក៏ងើបមើលថ្ងៃម្តង ឃើញដល់ពេលល្មមប្រស់ស្រួបហើយ ។ គាត់ត្រិះរិះថា « ឥឡូវអស់ពេលមួយភាគ៤ទៅហើយ ក្នុងមួយថ្ងៃវាមានបួនភាគ មិនទាន់ល្មមពេលទីងបត់នៅឡើយទេ អញគ្រាន់តែដោះស្បែកជើងសិន ។

គិតហើយ ដាក់ក្តុតអង្គុយដោះស្បែកជើង រួចខ្ចីឃាតដើរទៅទៀត ។

---

២—វៀកជាភាសារុស្ស៊ី ប្រវែងប្រហែលមួយគីឡូម៉ែត្រ

មើលកម្លាំងអាត្មាហាក់ដូចជានៅមាំទាំនៅឡើយ ប៉ាខុមគិតថា: «អញដើរប្រាំវៀកទៀតចុះ រួចសឹមអញបត់ទៅខាងឆ្វេង ៗ កន្លែងនេះចំជាល្អមែន! អញទៅបានឆ្ងាយកាលណា រឹតតែល្អកាលនោះ» ។

គាត់ចេះតែត្រេចព្រោះទៅខាងមុខ លុះងាកមើលមកក្រោយវិញ ឃើញភ្នំនៅឆ្ងាយលន្លោច មនុស្សនៅលើនោះ លេចឃើញតែខ្មៅតូចៗ ដូចជាសត្វល្អិត ប៉ាខុមគិតថា: «ណ្ហើយ! ល្មមបត់ទៅខាងនេះចុះ អញយកបានក៏ក្រៃលប៉ុណ្ណឹងដែរ!» ។

ប៉ុន្តែពេលនោះ ប៉ាខុមជោគញើសស្រោចខ្លួន ហើយថែមទាំងស្រេកទឹកផង គាត់លើកដបឡើងអកទឹកបណ្ដើរ ដើរបណ្ដើរ ៗ គាត់បង្គាប់ឲ្យគេបោះបង្គោលមួយ រួចទើបបត់ទៅខាងឆ្វេង ៗ ប៉ាខុមចេះតែដើរទៅដើរទៅ! ស្មៅក៏ខ្ពស់ៗ មេឃសោតក៏ក្ដៅ គាត់ចាប់ហត់បន្តិចៗ ។ ក្រឡេកមើលទៅថ្ងៃ ឃើញថាល្មមពេលបាយថ្ងៃត្រង់ ៗ ប៉ាខុមនឹកតែក្នុងពោះថា: «យីអើ! គួរតែអញសំរាកបន្តិចសិន» ។ ហ្នោះគាត់ក៏ឈប់ ហើយទាញនំប៉័ងមួយដុំមកអង្គៀម ប៉ុន្តែមិនហ៊ានដាក់ក្ដិតអង្គុយឡើយ ដ្បិតនឹកឃើញថា តែអង្គុយកាលណា «មុខជាចង់ប្រាសខ្លួនដេក តែដេកហើយមុខជាលក់លង់ទៅមិនខាន» ។ គាត់នៅទីនោះបានមួយស្របក់

ផកដង្ហើមយកខ្យល់ស្រួលហើយ ទើបដើរចេញទៅ ។

ប៉ាខ្ញុំគោបរដោយដំណើររវៀសរវៃ ពីព្រោះអាហារដែលទើបនឹងបរិភោគបានលើកកម្លាំងបន្តិចមកវិញ ប៉ុន្តែថ្ងៃក្តៅបេះតែនាំឲ្យទន់ត្របកភ្នែកងងុយដេក ។ ប៉ាខ្ញុំដឹងខ្លួនថាបាក់កម្លាំងមែនទែន ក៏ប៉ុន្តែនៅមានគំនិតមួយថា «ពិបាកមួយម៉ោងស្រណុកវិញមួយជីវិត» ។

គាត់ដើរសំដៅទៅចំហៀងខាងនោះ បានប្រមាណ ១០ វៀកទៀត លុះរៀបបត់ទៅខាងត្បូង ស្រាប់តែពេលទៅឃើញអូរមួយដ៏មានទឹកត្រជាក់ល្ហឹម ។ កើតមានគំនិតតែថា «បើអញចោលអូរនេះនៅក្រៅពីដីអញ ឃើញថាខាតជំនៃមួង ; ទឹកនេះជាថ្នាំជុះល្អណាស់» ។ ហ្នោះគាត់ក៏ដើរត្រង់ទៅទៀត ព័ទ្ធយកអូរបានហើយបោះបង្គោលមួយ ទើបបត់ជាគំរប់ទីពីរ ។ ងាកទៅក្រោយមើលភ្នំ ឃើញមនុស្សលឹម ៗ បាត់ទៅនឹងផ្ទៃភ្នំ ។ ប្រមាណមើលចម្ងាយពីនោះប្រហែល ១០ វៀក ប៉ាខ្ញុំនឹកថា «អញយកជ្រុងតាំងពីនេះវែងជ្រុលទៅហើយ ឥឡូវត្រូវយកជ្រុងថ្មីនេះឲ្យខ្លីបន្តិចចុះ» ។

គាត់ឈៀងតាមជ្រុងទីបី ដោយរន្ទន់ជំហានកាន់តែញាប់ឡើង ៗ ។ ក្រឡេកមើលទៅថ្ងៃឃើញជ្រេបន្តិចទៅហើយ ។ ប៉ាខ្ញុំដើរទើបតែបានពីរវៀកខាងចំហៀងទីបីនេះ ឯទីដើមនៅចម្ងាយដល់ទៅដប់ប្រាំវៀកទៀត ។

គាត់គិតថា: « ដីអញមិនបានស្មើជ្រុងស្មើជ្រោយក៏ហើយចុះ គប្បីអញគាត់ដម្រង់ទៅទីដើមវិញ ៗ ដីយកបានប៉ុណ្ណឹងក៏ល្មមដែរ » ៗ គិតហើយប៉ាខុមក៏ដើរត្រង់ឆ្ពោះទៅភ្នំតែម្ដង ៗ

ប៉ុន្តែប៉ាខុមអស់កម្លាំងណាស់ទៅហើយ ៗ ដើរតែដើរ ប៉ុន្តែជើងទាំងពីរឈឺចុក ហាក់ដូចជាខ្ទាំខ្ទុំទាំងអស់, គាត់ទន់ជង្គង់ស្ទើរលែះខ្លួនប្រាណទាំងស្រុង ៗ ចង់សម្រាកបន្តិចដែរ ប៉ុន្តែសំរាកមិនបានទេ តែហ៊ានសំរាកច្បាស់ជាទៅមិនដល់ទីដើមមុនថ្ងៃលិច ៗ ព្រះអាទិត្យមិនរង់ចាំគាត់ទេ ថែរជាធ្លាក់ចុះរិតរហាស់ឡើងទៅវិញ បីដូចជាមាននរណាទាញទំលាក់ដូច្នោះ ៗ ប៉ាខុមនឹកថា: « ឱ ! អញគិតខុសហើយ អញក្រសោបយកច្រើនហួសពេក ៗ បើអញទៅដល់ទីដើមមិនទាន់ពេលវេលា តើអញនឹងទៅជាអ្វី ? អញសោតក៏សែនអស់កម្លាំង ! ធ្វើម្ដេចកុំឲ្យតែអញបង់ទាំងប្រាក់ បង់ទាំងកម្លាំង ! ត្រូវតែដំនះទាល់តែបាន » ៗ

ប៉ាខុមតាំងតែរត់ត្រឹក ៗ បាទជើងរលាត់ចេញឈាមគ្មានសល់ ប៉ុន្តែគាត់ស៊ូតែរត់ហូត រត់ទៅ ! រត់ទៅ ! នៅតែឆ្ងាយទៀត ៗ គាត់គ្រវែងអាវសន្ទុះ ស្បែកជើង កន្តិបគាត់ចោលទាំងអស់ មកពិចារណាបណ្ដើរថា: « ហ៎ះ ! អញលោភច្រើនពេក អញខាតធំហើយ អញច្បាស់ជាទៅមិន

ដល់ទីដើមមុនថ្ងៃលិចទេ» ។

អំណាចភ័យពេក ចង់ផុតខ្យល់ម្តង ៗ ។

ប៉ាខុមពីតតែពីរត់ ញើសស្រាក់សើមអាវ-ខោទ្រនាប់ ជោកជាប់នឹងស្បែក មាត់ស្ងួតខ្សោះក្រទាំង ។ ដើមទ្រូងផតពោង ៗ ដូចជាស្នប់សប់ដុតដែក បេះដូងគ្រាំដូចញញ័រ ជើងលែងដឹងជាជើងផងទៅហើយ ប៉ាខុមទន់ជង្គង់មែនទែន ។ ម្តងនេះគាត់លែងគិតដល់ដីទៀតហើយ គិតតែកុំឲ្យស្លាប់ខ្លួនដោយសារហត់ដង្ហក់ គាត់ភ័យនឹងស្លាប់ទៅវិញ ។ ប៉ុន្តែមិនហ៊ានឈប់ទេ ដ្បិតគាត់គិតថា: «អញរត់មកបានច្រើនហើយ បើអញឈប់ទៅវិញ គេថាអញឆ្កួតជាមិនខាន» ។

គាត់ព្រួតព្រួកបាក់ស្គារហួច ស្រែកបញ្ឆោរពីចម្ងាយ ។ សូរសព្ទទាំងនេះ លើកទឹកចិត្តឲ្យក្លៀវក្លាជាងមុន ។ ប៉ាខុមបរចំណាយកម្លាំងស្តួចស្តើងនោះជាបង្ហើយដៃ ព្រោះអាទិត្យក៏ហាក់ដូចជាស្ទុះចុះលឿនថែមទៀត ។ ទីដើមមិននៅឆ្ងាយប៉ុន្មានទេ ប៉ាខុមមើលមនុស្សនៅលើភ្នំឃើញច្បាស់ ! គេបោយដៃឲ្យគាត់ប្រញាប់ឡើង ! គាត់គន់មើលឃើញកន្ទបនឹងប្រាក់គាត់ដែលដាក់នៅដី ឃើញទាំងនាយស្តារស្ហ៊ីណាអង្គុយស្អាបទៅជក្បាលនោះ ។ គាត់នឹកថា: «ដីបានច្រើនណាស់ ! តែព្រះលោកជួយអញឲ្យបានរស់នៅ

លើដីនោះទេ ? ឱ ! អញអើយ អញផុតហើយ,, ។ ហើយគាត់ត្រដររត់ទៅទៀត ។ មើលទៅថ្ងៃ ថ្ងៃក្រហមឆ្អាល រីកធំប៉ុនចង្អេរលិចទៅម្ខាងដី តែម្ខាងលិចបាត់ទៅហើយ ។ លុះប៉ាខ្ញុំរត់ដល់ជើងភ្នំ ថ្ងៃលិចបាត់ទាំងអស់ ។

ប៉ាខ្ញុំឈានមាត់ថា «ស្រេច---!,, ស្មានថាហិនប្រាក់ទៅហើយ ប៉ុន្តែមកនឹកឃើញទៀតថា បើគាត់នៅជើងភ្នំមើលថ្ងៃមិនឃើញ គេ ៗ នៅលើកំពូលភ្នំឃើញថ្ងៃមិនទាន់លិចនៅឡើយទេ,, ។ គាត់ស្ទុះឡើងភ្នំភ្លាម ឃើញកន្ទិបនៅជិតបង្កើយ ម្ដងនេះ ដល់ទីស្រេច ! ប៉ុន្តែ ប៉ាខ្ញុំពន្លូតជើងដួលទឹងកន្ទេង ដៃឈោងទៅចាប់កន្ទិបបាន ។ នាយស្ដារស្ហើណាស្រែកថា: « អើ ! សាធុអ្នកថ្ងៃ ! ឯងបានដីច្រើនណាស់,, ។

នេះជាសំដីបញ្ចើចបញ្ចើរទេ ដ្បិតប៉ាខ្ញុំដាច់ខ្យល់ស្លាប់នៅពេលនោះ ។ នាយស្ដារស្ហើណា បោះចបទៅឲ្យបាវម្នាក់ជីកដីកប់ ។ ប៉ាខ្ញុំបានដីតែបួនហត្ថល្មមខ្លួនគាត់តែប៉ុណ្ណោះ ។

X X

X

# ដំណឹងផ្សេងៗ

សមាគមរៀបចំធ្វើមហាសន្និបាតប្រចាំឆ្នាំនៅថ្ងៃ ២៩ មករា ១៩៥៧ ម៉ោង ២០ នៅទីសំណាក់ការលេខ ១៣០ វិថីប៉ាស្ទ័រ ។

របៀបវារៈ

១-សេចក្តីរាយការណ៍នៃលោកប្រធាន

២-សេចក្តីរាយការណ៍អំពីហិរញ្ញវត្ថុ

៣-ការជ្រើសតាំងគណកម្មាធិការថ្មី

ឃុំរពាណិជ្ជ
និមនៅ ផ្ទះលេខ ១៣៥ មហាវិថីព្រះសុរាម្រឹត

តម្លៃ១០រៀល